# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងអប់រំ យុវជន និងកីឡា**

# ការគ្រប់គ្រងសាលារៀនផ្តោតលើលទ្ធផល

## ឯកសារប្រតិបត្តិ

# ក្រុមប្រឹក្សាយុវជន និកុមារ

## សម្រាប់បឋមសិក្សា

**ឆ្នាំ ២០១៧**

# អារម្ភកថា

ផ្អែកលើនិន្នាការអប់រំសកលលោក ក្រសួងអប់រំ យុវជន និងកីឡាបានផ្តោតការយកចិត្តយ៉ាងខ្លាំងទៅលើការលើកកម្ពស់សិទ្ធិកុមារ ការថែទាំសុខភាព សុវត្ថិភាព ដោយបង្កឱកាសគ្រប់បែបយ៉ាងដើម្បីជួយឱ្យកុមារគ្រប់រូបបានចូលរៀនប្រកបដោយសមធម៌ និងគុណភាព។ ទន្ទឹមនឹងនោះ ក្រសួងអប់រំ យុវជន និងកីឡា បានបន្តពង្រឹងនូវយុទ្ធសាស្ត្រនៃការអនុវត្តកម្មវិធីសាលាកុមារមេត្រី ដើម្បីធានាបាននូវការដឹកនាំគ្រប់គ្រងសាលារៀន ការរៀន-ការបង្រៀនប្រកបដោយគុណភាព និងប្រសិទ្ធភាព។ប្រទេសកម្ពុជា បានផ្តល់សច្ចាប័នលើអនុសញ្ញាអង្គការសហប្រជាជាតិស្តីពីសិទ្ធិកុមារនៅថ្ងៃទី១៥ ខែតុលា ឆ្នាំ១៩៩២ យោងតាមខ្លឹមសារនៃអនុសញ្ញានេះដោយឡែកមាត្រា ១២ ១៣ ១៥ ១៧ និង៤២ បានលើកឡើងអំពីតួនាទីយ៉ាងសំខាន់របស់រដ្ឋជាភាគី ដែលត្រូវធានានូវឱកាសក្នុងការសម្តែងមតិ ការស្វែងរក និងទទួលព័ត៌មាន សិទ្ធិសេរីភាពផ្នែកគំនិតមនសិការ សាសនា សិទ្ធិបង្កើត ឬការចូលរួមសមាគម និងសិទ្ធិជួបជុំដោយសន្តិវិធី។

**ក្រុមប្រឹក្សាយុវជននិងកុមារសាលារៀន** រៀបចំឡើងសម្រាប់ជួយការងារក្នុងសាលារៀន និងផ្តល់ឱកាសឱ្យកុមារបានសិក្សារៀនសូត្របន្ថែមពីការងារដែលកើតមានឡើងក្នុងសាលារៀនជាក់ស្តែងមួយចំនួន ទាក់ទងទៅនឹងសកម្មភាពហ្វឹកហាត់ដឹកនាំនិងគ្រប់គ្រង ដើម្បីអាចអភិវឌ្ឍន៍បំណិនទទួលខុសត្រូវ ត្រិះរិះពិចារណា ដោះស្រាយបញ្ហា និងការប្រាស្រ័យទាក់ទងបន្ទាប់ពីការសិក្សាមុខវិជ្ជាក្នុងថ្នាក់រៀន។

លើសពីនោះទៅទៀត ក្រុមប្រឹក្សាយុវជននិងកុមារជាផ្នែកមួយនៃការពន្លឿនការងាររបស់សាលារៀនមួយចំនួនដូចជាការសិក្សា ការងារបណ្ណាល័យ ការងារសង្គម ការងាររដ្ឋបាល ការងារហិរញ្ញវត្ថុ ការផ្សព្វផ្សាយ ការងារសិល្បៈ កីឡា វប្បធម៌ ការងារសុខភាព អនាម័យ បរិស្ថាន បំណិនជីវិត និងក្លឹបសិក្សាតាមផ្ទះ និងភូមិ ព្រមទាំងជួយរួមចំណែកអភិវឌ្ឍន៍សាលារៀន ជួយខ្លួនឯងផ្ទាល់ឱ្យក្លាយជាសិស្សល្អ មិត្តល្អ កូនល្អ និងពលរដ្ឋល្អ សម្រាប់សាលារៀន និងសង្គមជាតិរបស់យើង។

# មាតិកា

**សេចក្តីផ្តើម**

**គោលបំណង**

ក កម្មវិធីក្រុមប្រឹក្សាយុវជននិងកុមារសម្រាប់សាលារៀន

ខ ភារកិច្ចក្រុមប្រឹក្សាយុវជននិងកុមារថ្នាក់រៀន និងសាលារៀន

១ ជួយខ្លួនឯង ក្នុងថ្នាក់រៀន
២ ជួយដល់សិស្សផ្សេងទៀត នៅក្នុងសាលារៀន
៣ ជួយដល់សិស្សផ្សេងទៀត នៅក្នុងនិងក្រៅសាលារៀន
៤ រាយការណ៍ ពីបញ្ហាដែលកើតឡើងចំពោះកុមារនៅសាលារៀន
៥ ដោះស្រាយបញ្ហាដែលកើតមានឡើងចំពោះកុមារនៅសាលារៀន

គ ដំណើរការជ្រើសរើស និងបង្កើតក្រុមប្រឹក្សាយុវជននិងកុមារថ្នាក់រៀន និងសាលារៀន

១ ការជ្រើសរើសប្រធាន អនុប្រធានសាខា ប្រធាន អនុប្រធាន និងសមាជិក
២ លក្ខណៈវិនិច្ឆ័យក្នុងការជ្រើសរើសប្រធាន អនុប្រធានសាខា ប្រធាន អនុប្រធាន និងសមាជិក
៣ ការប្រកាសជ្រើសរើសប្រធាន អនុប្រធានសាខា ប្រធាន អនុប្រធាន និងសមាជិក
៤ ការធ្វើយុទ្ធនាការជ្រើសរើសប្រធាន អនុប្រធានសាខា ប្រធាន អនុប្រធាន និងសមាជិក

ឃ សកម្មភាពការងារក្រុមប្រឹក្សាយុវជននិងកុមារថ្នាក់រៀន

១ ជួយសិស្សតាមថ្នាក់មានផែនការសកម្មភាពប្រចាំខែ
២ អនុវត្តស្វ័យវាយតម្លៃសិស្ស និងគ្រូបង្រៀនប្រចាំខែ
៣ សម្របសម្រួលក្រុមសិស្សឱ្យបង្កើត អនុវត្តគោលការណ៍(បទបញ្ជាផ្ទៃក្នុង)ថ្នាក់រៀន
៤ វាយតម្លៃការងារសកម្មភាពរបស់ថ្នាក់រៀន និងរាយការណ៍ទៅនាយក គណៈកម្មការទ្រទ្រង់សាលា

ង សកម្មភាពការងារក្រុមប្រឹក្សាយុវជននិងកុមារសាលារៀន

១ ជួយកុមារក្នុងថ្នាក់រៀន និងសាលារៀនលើការងាររៀនសូត្រ
២ ជួយកុមារឱ្យមានសមត្ថភាពរាយការណ៍ ពីបញ្ហាដែលកើតឡើងចំពោះកុមារនៅសាលារៀន
៣ ជួយកុមារឱ្យមានសមត្ថភាពក្នុងការដោះស្រាយបញ្ហា ដែលកើតមានឡើងចំពោះកុមារនៅសាលា

**ឧបសម្ព័ន្ធ**

**ឯកសារយោង**

# សេចក្តីផ្តើម

ប្រទេសកម្ពុជា បានផ្តល់សច្ចាប័នលើអនុសញ្ញាអង្គការសហប្រជាជាតិស្តីពីសិទ្ធិកុមារនៅថ្ងៃទី១៥ ខែតុលា ឆ្នាំ១៩៩២ យោងតាមខ្លឹមសារនៃអនុសញ្ញានេះដោយឡែកមាត្រា ១២ ១៣ ១៥ ១៧ និង៤២ បានលើកឡើងអំពីតួនាទីយ៉ាងសំខាន់របស់រដ្ឋជាភាគី ដែលត្រូវធានានូវឱកាសក្នុងការសម្តែងមតិ ការស្វែងរក និងទទួលព័ត៌មាន សិទ្ធិសេរីភាព ផ្នែកគំនិត មនសិការ សាសនា សិទ្ធិបង្កើត ឬចូលរួមសមាគម និងសិទ្ធិជួបជុំដោយសន្តិវិធី។

កុមារជាមុខសញ្ញាអ្នកទទួលសេវាអប់រំ រីឯគ្រូបង្រៀន នាយកសាលារៀន និងអ្នកពាក់ព័ន្ធជាអ្នកផ្តល់សេវាអប់រំ ដល់កុមារដើម្បីឱ្យគេអាចរៀនសូត្រ និងអភិវឌ្ឍន៍សមត្ថភាពទៅតាមស្តង់ដាកម្មវិធីសិក្សារបស់ក្រសួងអប់រំ យុវជន និងកីឡា គឺជាចំណែកមួយនៃការអនុវត្តសិទ្ធិកុមារនៅសាលារៀន ប្រកបដោយជោគជ័យ។ ដូច្នេះការស្តាប់យោបល់របស់កុមារ និងការបង្កឱកាសឱ្យកុមារបានចូលរួម ជួយឱ្យការសម្រេចចិត្តរបស់មនុស្សចាស់បានកាន់តែល្អប្រសើរ និងមានប្រសិទ្ធភាពដែលអាចឆ្លើយតបទៅនឹងតម្រូវការជាក់ស្តែងលើរាល់បញ្ហា ដែលពាក់ពន្ធ័នឹងកុមារ។ សកម្មភាពកុមារចូលរួម ក៏បានលើកស្ទួយនិងជួយឱ្យកុមារមានការអភិវឌ្ឍសមត្ថភាពរបស់ពួកគេ ក្នុងដំណើរការអភិវឌ្ឍសាលារៀន និងជាពិសេសបានលើកស្ទួយដល់គុណភាពសិក្សារៀនសូត្ររបស់គេ។

កម្មវិធីក្រុមប្រឹក្សាយុវជននិងកុមារ គឺរៀបចំឡើងសម្រាប់ជួយការងារក្នុងសាលារៀន និងផ្តល់ឱកាសឱ្យកុមារបានសិក្សារៀនសូត្របន្ថែមពីការងារដែលកើតមានឡើង ក្នុងសាលារៀនជាក់ស្តែងមួយចំនួនទាក់ទងទៅនឹងសកម្មភាពហ្វឹកហាត់ដឹកនាំ និងគ្រប់គ្រង ដើម្បីអាចអភិវឌ្ឍបំណិនទទួលខុសត្រូវ ការត្រិះរិះពិចារណា ការដោះស្រាយបញ្ហា និងការប្រាស្រ័យទាក់ទងបន្ទាប់ពីការសិក្សាមុខវិជ្ជាក្នុងថ្នាក់រៀន។ លើសពីនោះទៅទៀត ក្រុមប្រឹក្សាយុវជននិងកុមារជាផ្នែកនៃការពន្លឿនការងាររបស់សាលារៀនមួយចំនួន ដូចជា ការសិក្សា ការងារបណ្ណាល័យ ការងារសង្គ្រោះ ការជួយសង្គម ការងាររដ្ឋបាល ការងារហិរញ្ញវត្ថុ ការងារផ្សព្វផ្សាយ ការងារសិល្បៈកីឡា វប្បធម៌ ការងារសុខភាព ការងារអនាម័យបរិស្ថាន ការងារបំណិនជីវិត និងក្លឹបសិក្សាតាមផ្ទះ និងភូមិ។

ដូច្នេះកម្មវិធីក្រុមប្រឹក្សាយុវជននិងកុមារ ជាយន្តការមួយដ៏សំខាន់ជួយជំរុញដល់ការចូលរួមរបស់កុមារ និងការផ្តល់យោបល់ប្រកបដោយអត្ថន័យក្នុងសាលារៀន ដើម្បីរួមចំណែកអភិវឌ្ឍន៍សាលារៀន និងអភិវឌ្ឍន៍កុមារខ្លួនឯងផ្ទាល់ឱ្យក្លាយជាសិស្សល្អ មិត្តល្អ កូនល្អ និងពលរដ្ឋល្អ សម្រាប់សាលារៀន និងសង្គមជាតិយើង។

# គោលបំណង

១ ជួយអភិវឌ្ឍន៍សមត្ថភាពកុមារលើការទទួលខុសត្រូវ ការត្រិះរិះពិចារណា ការដោះស្រាយបញ្ហា ការប្រាស្រ័យទាក់ទង ការសម្រេចចិត្ត និងការតស៊ូរមតិដើម្បីអាចក្លាយទៅជាប្រជាពលរដ្ឋ ដែលមានសមត្ថភាព និងសក្តានុពលលើផ្នែកដឹកនាំ និងគ្រប់គ្រង។

២ ជួយផ្តល់គំនិតសម្រាប់ឱ្យសាលារៀន អាចច្នៃប្រឌិតក្នុងការរៀបចំកម្មវិធីក្រុមប្រឹក្សាយុវជននិងកុមារបត់បែនទៅតាមស្ថានភាពសាលារៀន និងតម្រូវការរបស់មូលដ្ឋានជាក់ស្តែង ដែលអាចឱ្យសាលារៀនអនុវត្តកម្មវិធីនេះទៅបាន ប្រកបដោយប្រសិទ្ធភាព និងមានប្រយោជន៍។

៣ ជួយនាយកសាលារៀន មានលទ្ធភាពអភិវឌ្ឍន៍សមត្ថភាព និងការគិតកាន់តែស៊ីជម្រៅមួយកម្រិតទៀត ក្នុងការប្រើប្រាស់គោលនយោបាយ សេចក្តីណែនាំ កម្មវិធីសិក្សា និងលិខិតបទដ្ឋានដែលបានផ្សព្វផ្សាយ ដោយក្រសួងអប់រំ យុវជន និងកីឡាឱ្យបានជាប្រយោជន៍សម្រាប់សិស្ស សម្រាប់សាលារៀន និងសហគមន៍។

## ក កម្មវិធីក្រុមប្រឹក្សាយុវជននិងកុមារសម្រាប់សាលារៀន

ការរៀបចំឱ្យមានកម្មវិធី ក្រុមប្រឹក្សាយុវជននិងកុមារនៅកម្រិតសាលារៀន គឺមានសារៈសំខាន់ជាទីបំផុតក្នុងការសម្របសម្រួលជួយឱ្យសកម្មភាពក្រុមប្រឹក្សាយុវជននិងកុមារ នៅកម្រិតសាលារៀនមានលក្ខណៈជាក់ស្តែងដែលសមស្របទៅនឹងស្ថានភាពរបស់មូលដ្ឋាន និងអាចអនុវត្តបានប្រកបដោយគុណភាព និងប្រសិទ្ធភាព។

ការរៀបចំកម្មវិធីក្រុមប្រឹក្សាយុវជននិងកុមារ នៅកម្រិតសាលារៀន គឺជាគំនិតផ្តួចផ្តើមប្រកបដោយភាពម្ចាស់ការរបស់នាយកសាលារៀនក្នុងការចលនាឱ្យមានការចូលរួមពីសំណាក់អ្នកពាក់ព័ន្ធទាំងឡាយ ក្នុងសាលារៀន និងសហគមន៍ ជាពិសេសទៅទៀត គឺការចលនាឱ្យសិស្សានុសិស្សក្នុងសាលារៀនទាំងអស់ បានចូលរួមក្នុងសកម្មភាពក្រុមប្រឹក្សាយុវជននិងកុមារ ដែលនឹងនាំមកនូវផលប្រយោជន៍ ដ៏ធំធេងសម្រាប់កុមារផ្ទាល់ ក្នុងការអភិវឌ្ឍសមត្ថភាពជាកូនល្អ សិស្សល្អ និងមិត្តល្អព្រមទាំងក្លាយជាពលរដ្ឋល្អ។

ការរៀបចំកម្មវិធីក្រុមប្រឹក្សាយុវជននិងកុមារ នៅកម្រិតសាលារៀន គឺជាការបំលែងគោលបំណង គោលការណ៍ និងខ្លឹមសារសំខាន់ៗដែលមានស្រាប់ក្នុងគោលនយោបាយ សេចក្តីណែនាំ និងឯកសារសំខាន់ៗអំពីសិទ្ធិកុមារ ដែលបានផ្សព្វផ្សាយ និងដាក់ឱ្យប្រើប្រាស់កន្លងមករបស់ក្រសួងអប់រំ យុវជន និងកីឡាឱ្យក្លាយទៅជាឯកសារសម្រាប់ប្រតិបត្តិជាក់ស្តែងបាននៅក្នុងសាលារៀន។

ដូច្នេះសកម្មភាពប្រតិបត្តិទាំងឡាយ នៃការងារក្រុមប្រឹក្សាយុវជននិងកុមារ នៅកម្រិតសាលារៀន គឺជាមធ្យោបាយសម្រាប់ជួយដល់ការបណ្តុះបណ្តាលកុមារ បន្ថែមទៀតលើការសិក្សាមុខវិជ្ជាក្នុងកម្មវិធីសិក្សារបស់ក្រសួងអប់រំ យុវជន និងកីឡា ឱ្យមានការអភិវឌ្ឍសមត្ថភាពជាអ្នកដឹកនាំ និងជាអ្នកគ្រប់គ្រងអំពីកិច្ចការអប់រំ សេដ្ឋកិច្ច និងសង្គមក្នុងកម្រិតសាលារៀន និងក្នុងសហគមន៍តាមរយៈការហ្វឹកហាត់ ការសម្រេចចិត្ត ការដោះស្រាយបញ្ហា ការចូលរួមសកម្មភាពសង្គម និងការតស៊ូមតិសម្រាប់ជាប្រយោជន៍ដល់កុមារទាំងក្នុង និងក្រៅសាលារៀន។

សកម្មភាពប្រតិបត្តិនៃកម្មវិធីក្រុមប្រឹក្សាយុវជននិងកុមារ សម្រាប់សាលារៀន គឺការផ្តើមឡើងពីការជួយឱ្យកុមារមាន៖ (១)សមត្ថភាពជួយខ្លួនឯងក្នុងការរៀនសូត្រ (២)សមត្ថភាពសម្របសម្រួលជួយដល់កុមារផ្សេងទៀតក្នុងថ្នាក់រៀន និងសាលារៀន (៣)សមត្ថភាពរាយការណ៍ពីបញ្ហាដែលកើតឡើងចំពោះកុមារក្នុងសាលារៀន និងសហគមន៍ (៤)សមត្ថភាពក្នុងការដោះស្រាយបញ្ហាតាមរយៈការចូលរួមប្រជុំជាផ្លូវការ និងមិនផ្លូវការជាមួយអ្នកពាក់ព័ន្ធក្នុងសាលារៀន ដើម្បីអាចធ្វើការតស៊ូមតិអំពីផលប្រយោជន៍របស់កុមារក្នុងការសិក្សារៀនសូត្រ និងការរស់នៅប្រចាំថ្ងៃ។

## ខ ភារកិច្ចក្រុមប្រឹក្សាយុវជននិងកុមារថ្នាក់រៀន និងសាលារៀន

### ១ ជួយខ្លួនឯងក្នុងថ្នាក់រៀន

ក្រុមប្រឹក្សាយុវជននិងកុមាររបស់សាលារៀន គឺជួយដល់សាខាក្រុមប្រឹក្សាយុវជននិងកុមារតាមថ្នាក់រៀនឱ្យជួយកុមារម្នាក់ៗក្នុងថ្នាក់រៀន ជាពិសេសសម្រាប់សិស្សថ្នាក់ទី៤ ទី៥ និងទី៦ ឱ្យមានផែនការសកម្មភាពផ្ទាល់ខ្លួនប្រចាំខែ (ឧបសម្ព័ន្ធទី១៖ ឧទាហរណ៍តារាងផែនការសកម្មភាពប្រចាំខែសម្រាប់សិស្សម្នាក់ៗ)។ ខ្លឹមសាររបស់ផែនការសកម្មភាព គឺផ្តោតទៅលើះ(១)លទ្ធផលសិក្សា និងសកម្មភាពសិក្សាដោយខ្លួនឯង (២)លទ្ធផលសិក្សា និងសកម្មភាពសិក្សាជាមួយមិត្តរួមថ្នាក់ ឬជួយដល់មិត្តរួមថ្នាក់ក្នុងការសិក្សា។ល។

ក្រៅពីនេះ ក្រុមប្រឹក្សាយុវជននិងកុមារសាលារៀន អាចជួយដល់សាខាក្រុមប្រឹក្សាយុវជននិងកុមារតាមថ្នាក់រៀនឱ្យអនុវត្តការធ្វើស្វ័យវាយតម្លៃលទ្ធផល ដែលទាក់ទងទៅនឹងសកម្មភាពកុមារបានជួយខ្លួនឯង និងកុមារមានការជួយផ្ទាល់ពីសំណាក់គ្រូបង្រៀន។ ខ្លឹមសារនៃការវាយតម្លៃ គឺផ្តោតទៅលើការលុបបំបាត់អំពើហិង្សា ការកេងប្រវ័ញ្ចលើកុមារ ការបង្កើនគុណភាពលទ្ធផលសិក្សា ការលើកកម្ពស់សុខភាពអនាម័យ និងបំណិនជីវិតនៅសាលារៀន...។ (ឧបសម្ព័ន្ធទី២៖ ឧទាហរណ៍តារាងស្វ័យវាយតម្លៃរបស់សិស្ស និងរបស់គ្រូបង្រៀនប្រចាំខែ)

## ២ ជួយដល់សិស្សផ្សេងទៀត នៅក្នុងសាលារៀន

ក្រុមប្រឹក្សាយុវជននិងកុមាររបស់សាលារៀន គឺជួយដល់សាខាក្រុមប្រឹក្សាយុវជននិងកុមារតាមថ្នាក់រៀនទាំងអស់ ឱ្យអនុវត្តសកម្មភាពសំខាន់ៗមួយចំនួនរបស់សាលារៀន មានដូចជា៖ (១)ផ្នែកវិន័យនិងចលនាកុមារបីល្អ(២)ផ្នែកសិក្សា និងបណ្ណាល័យ(៣)ផ្នែកសង្គ្រោះនិងជួយសង្គម(៤)ផ្នែករដ្ឋបាលនិងហិរញ្ញវត្ថុ(៥)ផ្នែកផ្សព្វផ្សាយ(៦)ផ្នែកសិល្បៈ កីឡា និងវប្បធម៌ (៧)ផ្នែកសុខភាព អនាម័យ បរិស្ថាន និងបំណិនជីវិត (៨)ផ្នែកក្លឹបសិក្សាតាមផ្ទះ និងតាមភូមិ នៅក្នុងសហគមន៍ដែលអាចជួយកុមារក្នុងសាលារៀន និងក្រៅសាលារៀនបានរៀនជាមួយគ្នាបន្ថែមក្រៅពីរៀននៅសាលារៀន។ សូមមើលសេចក្តីលម្អិត (ឯកសារយោងទី១៖ កម្មវិធីសាលាកុមារមេត្រីសមាសភាពទី៥ការចូលរួមរបស់កុមារ គ្រួសារនិងសហគមន៍ <u>ប្រតិបត្តិរបស់ក្រុមប្រឹក្សាយុវជននិងកុមារបោះពុម្ពឆ្នាំ២០១០</u>)

## ៣ ជួយដល់សិស្សផ្សេងទៀត នៅក្នុងនិងក្រៅសាលារៀន

ក្រៅពីកិច្ចការរបស់សាលារៀន ដូចបានរៀបរាប់ខាងលើ ក្រុមប្រឹក្សាយុវជននិងកុមារសាលារៀនចូលរួមជួយប្រមូលកុមារក្រៅសាលា ឱ្យបានចូលរៀនតាមរយៈសកម្មភាពមួយចំនួនដូចជា៖ ការជួយកំណត់មុខសញ្ញាកុមារក្រៅសាលារៀនដែលរស់នៅផ្ទះជិតគ្នា ភូមិជាមួយគ្នា និងអាចរាយការណ៍ ទៅបណ្តាញសាលារៀន (មេក្រុម មេភូមិ គ្រូបង្រៀន និងនាយកសាលារៀន)។

កិច្ចការមួយទៀត គឺការជួយដល់កុមារលើការរៀនសូត្រ ទាំងនៅក្នុងថ្នាក់ និងក្នុងសាលារៀន។ ក្នុងនោះក្រុមប្រឹក្សាយុវជននិងកុមារសាលារៀន ជួយដល់សាខាក្រុមប្រឹក្សាយុវជននិងកុមារថ្នាក់រៀន ឱ្យជួយគ្នារៀបចំកន្លែងរៀននៅផ្ទះខ្លួនឯង ផ្ទះអ្នកជិតខាង និងកន្លែងរៀនក្នុងសហគមន៍ ដោយមានការជួយ

ដាស់តឿនឱ្យរៀនសូត្រ ឬជួយបង្រៀនពីសំណាក់បងនិងប្អូនជាអ្នករៀនដូចគ្នា ឪពុកម្ដាយ មីងមា យាយតា ដែលស្ម័គ្រចិត្តជួយសម្របសម្រួលដល់ដំណើរការរៀនសូត្របានជាប្រចាំ។ គ្រូបង្រៀនអាចធ្វើការតាមដានដំណើរការរៀនសូត្របានដោយជួយឱ្យក្រុមប្រឹក្សាយុវជននិងកុមារមានលទ្ធភាពជួយកុមាររៀងៗខ្លួន និងក្នុងក្រុមឱ្យមានសៀវភៅសម្រាប់កត់ត្រា។ (ឧបសម្ព័ន្ធទី៣.ក៖ ឧទាហរណ៍បញ្ជីឈ្មោះកូនក្មួយដែលត្រូវរៀន ឈ្មោះអ្នកសម្របសម្រួលជួយដាស់តឿនកូនក្មួយបានរៀន ម៉ោងរៀន សម្រាប់រៀននូវផ្ទះខ្លួនឯង និងឧបសម្ព័ន្ធទី៣.ខ៖ ឧទាហរណ៍ការរៀបចំសៀវភៅកត់ត្រាដំណើរការកន្លែងរៀន ផ្ទះជិតគ្នា និងកន្លែងរៀនក្នុងសហគមន៍ដោយបញ្ជាក់ ម៉ោងរៀន មេរៀន និងអ្នកបានមករៀន)។


សកម្មភាពម្ដាយជួយបង្រៀនកូននៅផ្ទះ


សកម្មភាពបងជួយបង្រៀនប្អូននៅផ្ទះ


សកម្មភាពសិស្សរៀននូវកន្លែងប្រមូលផ្ដុំក្នុងសហគមន៍


សកម្មភាពសិស្សរៀននូវផ្ទះជិតគ្នា

សរុបមកកន្លែងរៀន និងដំណើរការរៀនសូត្រនេះប្រព្រឹត្តទៅបានដោយមានការគ្រប់គ្រងចាត់ចែង និងទទួលខុសត្រូវដោយផ្ទាល់ ពីសំណាក់មេភូមិ មេឃុំ បុព្វជិតសាសនា ឬអ្នកពាក់ព័ន្ធដទៃទៀត ដោយមានការសហការជាមួយគ្រូបង្រៀន ក្រុមប្រឹក្សាយុវជននិងកុមាររបស់សាលារៀន និងគណៈគ្រប់គ្រងសាលារៀនផងដែរ។

ក្រៅពីរៀបចំកន្លែងរៀនដូចបានរៀបរាប់ខាងលើ ក្រុមប្រឹក្សាយុវជននិងកុមារក៏ត្រូវមានភារកិច្ចរៀបចំឱ្យមានសកម្មភាពប្រកួតអានក្នុងថ្នាក់ រវាងថ្នាក់និងថ្នាក់ ក្នុងសាលារៀន ដើម្បីយកលទ្ធផលនោះទៅប្រកួតផ្ដាច់ព្រ័ត្ររវាងសាលា និងសាលាជារៀងរាល់ឆ្នាំ។(ឧបសម្ព័ន្ធទី៤៖ ដំណើរការរៀបចំព្រឹត្តការណ៍ប្រកួតអំណាន)


សកម្មភាពសិស្សប្រកួតអំណាននៅតាមថ្នាក់រៀន


សកម្មភាពសិស្សប្រកួតអំណាននៅសាលារៀន

### ៤ រាយការណ៍ ពីបញ្ហាដែលកើតឡើងចំពោះកុមារនៅសាលារៀន

ក្រុមប្រឹក្សាយុវជននិងកុមាររបស់សាលារៀន គឺជួយដល់សាខាក្រុមប្រឹក្សាយុវជននិងកុមារតាមថ្នាក់រៀនដើម្បីបានជួយដល់សិស្សក្នុងថ្នាក់ទាំងអស់ ឱ្យបានដឹងពីប្រព័ន្ធរាយការណ៍ រាល់បញ្ហាទាំងឡាយដែលអាចកើតឡើងចំពោះកុមារ ទាក់ទងទៅនឹងអំពើហិង្សា ការកេងប្រវ័ញ្ចកម្លាំងពលកម្ម និងការរំលោភបំពានផ្សេងៗ។ ពេលមានបញ្ហាកុមារនឹងត្រូវរាយការណ៍ជូន៖ តំណាងក្រុមប្រឹក្សាយុវជននិងកុមារតាមថ្នាក់ តំណាងក្រុមប្រឹក្សា កុមាររបស់សាលារៀន តំណាងគ្រូបង្រៀន នាយកឬនាយករង ប្រធានក្រុម មេភូមិ មេឃុំ នគរបាលប៉ុស្តិ៍រដ្ឋបាល និងអ្នកពាក់ព័ន្ធមួយចំនួនទៀត ដែលគណៈកម្មការអភិវឌ្ឍសាលារៀនបានរៀបចំសម្រាប់ឱ្យសិស្សអាចមានជម្រើសក្នុងការរាយការណ៍ និងទទួលបានសេវាគាំទ្រ។ (ឧបសម្ព័ន្ធទី៥៖ ឧទាហរណ៍តារាង ប្រព័ន្ធរាយការណ៍ និងផ្តល់សេវាដល់កុមារជួបការលំបាក និងរងគ្រោះ)

តារាងប្រព័ន្ធរាយការណ៍ និងផ្តល់សេវាដល់កុមារ នឹងត្រូវធ្វើការផ្សព្វផ្សាយដល់សិស្សទាំងអស់ក្នុងសាលារៀនជារៀងរាល់ខែនៅពេលគោរពទង់ជាតិ ឬមុនពេលចេញទៅផ្ទះ ដោយក្រុមប្រឹក្សាយុវជននិងកុមារជាមួយនគរបាលប៉ុស្តិ៍រដ្ឋបាល។ ក្រៅពីការផ្សព្វផ្សាយ ក៏មានការបិទនៅក្នុងសាលារៀន នៅតាមផ្ទះមួយចំនួន និងនៅទីកន្លែងសំខាន់ៗមួយចំនួនទៀតក្នុងសហគមន៍បន្ថែមទៀត។

### ៥ ដោះស្រាយបញ្ហា ដែលកើតមានឡើងចំពោះកុមារនៅសាលារៀន

ក្រុមប្រឹក្សាយុវជននិងកុមាររបស់សាលារៀន គឺជួយដល់សាខាក្រុមប្រឹក្សាយុវជននិងកុមារតាមថ្នាក់រៀនទាំងអស់ បានប្រមូលទិន្នន័យនិងព័ត៌មាន ព្រមទាំងរាយការណ៍ពីអ្វីដែលកើតមានឡើង នៅតាមថ្នាក់រៀន និងសាលារៀនប្រចាំខែមានដូចជា៖(១)លទ្ធផលការងារធ្វើផែនការសកម្មភាពរបស់សិស្សម្នាក់ៗតាមថ្នាក់ (២)លទ្ធផលនៃការស្វ័យវាយតម្លៃសិស្សគ្រូប្រចាំខែការអនុវត្តការងារក្រុមប្រឹក្សាយុវជននិងកុមារតាមថ្នាក់ និង(៣)លទ្ធផលនៃការអនុវត្តសកម្មភាពក្រុមប្រឹក្សាយុវជននិងកុមារ ក្នុងសាលារៀនទាំង ៨ផ្នែក (ក្នុងចំណុច ខ.២)។

ជារៀងរាល់ខែ តំណាងក្រុមប្រឹក្សាសាលារៀន ចូលរួមប្រជុំជាមួយគណៈកម្មការអភិវឌ្ឍសាលារៀន គណៈគ្រប់គ្រងសាលារៀន និងគ្រូទទួលបន្ទុកថ្នាក់ដើម្បីគេអាចរាយការណ៍ពីលទ្ធផលរីកចម្រើនបញ្ហាប្រឈមពីផែនការសកម្មភាពដែលនឹងត្រូវធ្វើបន្តនៅខែបន្ទាប់ និងសំណូមពរដល់អ្នកពាក់ព័ន្ធដើម្បីជួយដោះស្រាយ។ លើសពីនោះទៅទៀត តំណាងក្រុមប្រឹក្សាយុវជននិងកុមារក៏អាចយកលទ្ធផលរីកចម្រើន និងបញ្ហាប្រឈមទាំងនោះជូនអង្គប្រជុំជាមួយក្រុមប្រឹក្សាឃុំ សង្កាត់ និងស្ថាប័នផ្សេងទៀតផងដែរ។

## គ ដំណើរការជ្រើសរើស និងបង្កើតក្រុមប្រឹក្សាយុវជននិងកុមារថ្នាក់រៀន និងសាលារៀន

## ១ ការជ្រើសរើស ប្រធាន អនុប្រធានសាខា ប្រធាន អនុប្រធាន និងសមាជិកគណៈកម្មាធិការប្រតិបត្តិ

ជារៀងរាល់ដើមឆ្នាំសិក្សា សាលារៀនមានការជ្រើសរើសសមាសភាព សម្រាប់បង្កើតក្រុមប្រឹក្សាយុវជននិងកុមារ តាមថ្នាក់ និងសាលារៀន ដោយជ្រើសរើសយកសមាសភាពសិស្ស ដែលមានការស្ម័គ្រចិត្តដោយឈរឈ្មោះសម្រាប់ឱ្យគេបោះឆ្នោត។ បេក្ខជនដែលត្រូវជ្រើសរើសតាមរយៈការបោះឆ្នោត គឺជាការជ្រើសរើសរក ប្រធាននិងអនុប្រធានសាខា បន្ទាប់មកទើបជ្រើសរើសប្រធាន អនុប្រធាន និងសមាជិកគណៈកម្មាធិការប្រតិបត្តិ។ ប្រធាន អនុប្រធាន និងសមជិកគណៈកម្មាធិការប្រតិបត្តិត្រូវមានការចូលរួមពីកុមារីផងដែរ។

## ២ លក្ខណៈវិនិច្ឆ័យក្នុងការជ្រើសរើស ប្រធាន អនុប្រធានសាខា ប្រធាន អនុប្រធាន និងសមាជិកគណៈកម្មាធិការប្រតិបត្តិ

សាលារៀនរៀបចំលក្ខណៈវិនិច្ឆ័យ សម្រាប់ផ្សព្វផ្សាយដល់សិស្សទាំងអស់ ក្នុងសាលារៀន ជាពិសេសសិស្សថ្នាក់ទី៤ ទី៥ និងទី៦ ដើម្បីដាក់ពាក្យជាបេក្ខភាពឈរឈ្មោះ ដើម្បីឱ្យគេបោះឆ្នោតជ្រើសរើសជាក្រុមប្រឹក្សាយុវជននិងកុមារសាខាប្រចាំថ្នាក់រៀន និងគណៈកម្មាធិការប្រតិបត្តិប្រចាំសាលារៀន។ ចំពោះកម្រិតសាលារៀន បើបេក្ខជនសិស្សមកពីថ្នាក់ណា ដែលត្រូវបានគេជ្រើសរើសជាតំណាងក្រុមប្រឹក្សាយុវជននិងកុមារកម្រិតថ្នាក់រៀនរួចហើយ និងត្រូវបានគេបន្តបោះឆ្នោតជ្រើសរើស ជាបេក្ខភាពប្រចាំសាលារៀនទៀត តែលុះត្រាតែបេក្ខភាពនេះមានប្រជាប្រិយភាពជាងគេខ្លាំងណាស់ និងមានតម្លៃសម្រាប់សិស្សរួមថ្នាក់និងមិត្តភក្តិក្នុងភូមិផងដែរ។ លក្ខណៈវិនិច្ឆ័យក្នុងការជ្រើសរើស សំខាន់ៗមានដូចជា៖ បេក្ខជននោះជាសិស្ស (១)ឧស្សាហ៍រៀនសូត្រ (២)ឧស្សាហ៍ជួយការងារគ្រួសារ (៣)ឧស្សាហ៍ជួយការងារថ្នាក់រៀន និងសាលារៀន (៤)មិនឈ្លោះប្រកែកជាមួយមិត្តភក្តិ (៥)មិនជេរ ឬវាយដំមិត្តភក្តិ (៦)ជួយយកអាសារមិត្តភក្តិក្នុងការរៀនសូត្រ (៧)ជួយយកអាសារមិត្តភក្តិ ក្នុងការងារសង្គម (៨)ជួយគ្រូបង្រៀន និងនាយកសាលារៀន តាមរយៈការស្តាប់និងធ្វើតាមដំបូន្មានល្អៗ ។ល។

## ៣ ការប្រកាសជ្រើសរើសប្រធាន អនុប្រធានសាខា ប្រធាន អនុប្រធាន និងសមាជិក គណៈកម្មាធិការប្រតិបត្តិ

សាលារៀនកំណត់កាលបរិច្ឆេទនៃការដាក់ពាក្យនិងឈប់ទទួលពាក្យរបស់សិស្សតាមថ្នាក់នីមួយៗដែលជាអ្នកឈរឈ្មោះបេក្ខជនសម្រាប់បោះឆ្នោតជ្រើសរើស ជាក្រុមប្រឹក្សាយុវជននិងកុមារកម្រិតថ្នាក់រៀននិងគណៈកម្មាធិការប្រតិបត្តិប្រចាំសាលារៀន។

ការប្រកាសជ្រើសរើស មានបិទផ្សាយនៅតាមថ្នាក់រៀន នៅសាលារៀន និងនៅសហគមន៍។ ការប្រកាសនេះក៏មានភ្ជាប់ជាមួយលក្ខណៈវិនិច្ឆ័យនៃការជ្រើសរើសបេក្ខជន សម្រាប់បង្កើតក្រុមប្រឹក្សាយុវជន

និងកុមារផងដែរ។ ការប្រកាសនេះក៏មានការចូលរួម និងដឹងឮពីសំណាក់សាលារៀន អាជ្ញាធរដែនដី និងសហគមន៍ដើម្បីឱ្យការជ្រើសរើសក្រុមប្រឹក្សាយុវជននិងកុមារនេះមានតម្លៃ និងបង្កើនឱ្យមានមោទនភាពសម្រាប់សាលារៀន ជាពិសេសសម្រាប់កុមារ និងក្រុមគ្រួសារដែលបានជាប់ឆ្នោតជាក្រុមប្រឹក្សាយុវជននិងកុមារប្រចាំថ្នាក់ និងសាលារៀន។ លើសពីនេះទៅទៀតសម្រាប់ជួយឱ្យកុមារប្រឹងប្រែងរៀនសូត្រ និងធ្វើអំពើល្អសម្រាប់សាលារៀន និងសហគមន៍។

### ៤ ការធ្វើយុទ្ធនាការជ្រើសរើស ប្រធាន អនុប្រធានសាខា ប្រធាន អនុប្រធាន និងសមាជិកគណៈកម្មាធិការប្រតិបត្តិ

សាលារៀនរៀបចំជាគោលការណ៍ សម្រាប់ណែនាំធ្វើយុទ្ធនាការឃោសនារបស់បេក្ខភាពដែលដាក់ពាក្យក្នុងកម្រិតថ្នាក់រៀន ដើម្បីស្វែងរកការគាំទ្រពីមិត្តរួមថ្នាក់។ រីឯបេក្ខជនដាក់ពាក្យជាក្រុមប្រឹក្សាយុវជននិងកុមារ គណៈកម្មាធិការប្រតិបត្តិសាលារៀន ត្រូវការស្វែងរកការគាំទ្រពីសំណាក់កុមារទាំងអស់ក្នុងសាលារៀន។ យុទ្ធនាការនេះមានរៀបចំជាពិធីធ្វើបទបង្ហាញ និងការសួរសំណួរពីសំណាក់គ្រូបង្រៀន នាយកសាលារៀន សហគមន៍ និងសិស្សានុសិស្ស។ បញ្ជីឈ្មោះបេក្ខជន នឹងត្រូវមានការបិទបង្ហាញជាសាធារណៈនៅក្នុងថ្នាក់រៀន សាលារៀន និងសហគមន៍។ រីឯការបោះឆ្នោត គឺសាលារៀនរៀបចំជាគណៈកម្មការវាយតម្លៃសាលារៀន ដែលជាអ្នកជួយធ្វើជាអាជ្ញាកណ្តាល។

## ឃ សកម្មភាពការងារក្រុមប្រឹក្សាយុវជននិងកុមារថ្នាក់រៀន

### ១ ជួយដល់សិស្សតាមថ្នាក់មានផែនការសកម្មភាពប្រចាំខែ

ក្រុមប្រឹក្សាយុវជននិងកុមារតាមថ្នាក់ជួបជុំសិស្សទាំងអស់ក្នុងថ្នាក់ដោយយកពេលណាមួយ ដើម្បីពិភាក្សាជួយសិស្សម្នាក់ៗតាមថ្នាក់ឱ្យធ្វើផែនការសកម្មភាពរបស់ខ្លួនប្រចាំខែ។ ផែនការសកម្មភាពរបស់សិស្សម្នាក់ៗមានបង្ហាញពីលទ្ធផលរំពឹងទុក និងសកម្មភាពសម្រាប់អនុវត្តប្រចាំខែនីមួយៗ(ឧបសម្ព័ន្ធទី១៖ ឧទាហរណ៍តារាងផែនការសកម្មភាពប្រចាំខែរបស់សិស្សម្នាក់ៗ)។ ខ្លឹមសារសម្រាប់សិស្សកំណត់ក្នុងផែនការសកម្មភាពប្រចាំខែ គឺជាបញ្ហាដែលសិស្សជួបការលំបាក ក្នុងការសិក្សាដូចជា៖ លំបាកអាន លំបាកសរសេរ លំបាកធ្វើលំហាត់ឬចំណោទ។ល។

ផែនការសកម្មភាពប្រចាំខែរបស់សិស្សម្នាក់ៗ អាចសរសេរក្នុងសៀវភៅកត់មេរៀន ឬសៀវភៅលំហាត់ក៏បានអាស្រ័យទៅលើលទ្ធភាពរបស់សិស្សម្នាក់ៗ។ ក្រោយពីបានសរសេរផែនការសកម្មភាពរួចហើយ សិស្សម្នាក់ៗ ត្រូវអានខ្លឹមសារក្នុងផែនការសកម្មភាពឱ្យឮៗ ដើម្បីឱ្យសិស្សផ្សេងទៀតបានស្តាប់ជាសាក្សី។

ផែនការសកម្មភាពប្រចាំខែរបស់សិស្សម្នាក់ៗនឹងត្រូវរាយការណ៍ដោយសិស្សខ្លួនឯងផ្ទាល់ ដល់មិត្តរួមថ្នាក់ ក្រុមប្រឹក្សាយុវជននិងកុមារ និងគ្រូបង្រៀននៅរៀងរាល់ខែ។ ការធ្វើរបាយការណ៍លទ្ធផលសម្រេចបានប្រចាំខែប្រៀបធៀបជាមួយលទ្ធផលរំពឹងទុក ដែលបានកំណត់ក្នុងផែនការសកម្មភាពរបស់ខ្លួន។ បន្ទាប់មកបន្តធ្វើផែនការសកម្មភាពសម្រាប់ខែក្រោយ។

## ២ អនុវត្តស្វ័យវាយតម្លៃសិស្ស និងគ្រូបង្រៀនប្រចាំខែ

ក្រុមប្រឹក្សាយុវជននិងកុមាររបស់សាលារៀន ជួបជុំជាមួយសិស្សទាំងអស់ក្នុងថ្នាក់ ដោយជ្រើសរើសយកពេលណាមួយ ដែលមិនប៉ះពាល់ដល់ម៉ោងរៀនសូត្រ ដើម្បីពិភាក្សាគ្នាជួយដល់សិស្សតាមថ្នាក់ម្នាក់ៗ ឱ្យធ្វើស្វ័យវាយតម្លៃរបស់ខ្លួន និងរបស់គ្រូបង្រៀនប្រចាំខែ។ ស្វ័យវាយតម្លៃរបស់សិស្សម្នាក់ៗ និងរបស់គ្រូ មានកំណត់សូចនាករច្បាស់លាស់ និងមានដាក់ចំនួនសិស្សតាមខែ (ឧបសម្ព័ន្ធទី២៖ ឧទាហរណ៍តារាងស្វ័យវាយតម្លៃរបស់សិស្ស និងរបស់គ្រូបង្រៀនប្រចាំខែ)។ ខ្លឹមសារសកម្មភាពសម្រាប់សិស្សដែលកំណត់ក្នុងតារាងស្វ័យវាយតម្លៃរបស់សិស្សម្នាក់ៗ និងរបស់គ្រូបង្រៀន គឺជាសកម្មភាពដែលសិស្សតាមថ្នាក់ត្រូវកត់សម្គាល់ដូចជា ៖ ការសួរសំណួរ ការធ្វើទំនាក់ទំនង និងការផ្តល់ព័ត៌មានត្រឡប់ពីការសិក្សា ការប៉ះទង្គិចពីមិត្តភក្តិ ពីគ្រូនៅសាលារៀន និងពីមនុស្សជំផ្សេងទៀត។ល។

ចំពោះឧបករណ៍ស្វ័យវាយតម្លៃប្រចាំខែរបស់សិស្សម្នាក់ៗ និងរបស់គ្រូបង្រៀន សិស្សអាចសរសេរក្នុងសៀវភៅកត់មេរៀន ក្រដាសរ៉ាម ឬតាមមធ្យោបាយផ្សេងទៀតក៏បាន អាស្រ័យទៅតាមលទ្ធភាពរបស់សិស្សម្នាក់ៗអាចធ្វើបាន។ បន្ទាប់ពីបង្កើតបានឧបករណ៍ស្វ័យវាយតម្លៃរួចហើយ សិស្សម្នាក់ៗត្រូវអានខ្លឹមសារស្វ័យវាយតម្លៃនោះ ដោយប្រកាសច្បាស់ៗ ឮៗ ដើម្បីឱ្យសិស្សផ្សេងៗទៀត និងគ្រូបង្រៀនបានស្តាប់បានដឹង និងបញ្ជាក់ថាមានឧបករណ៍ធ្វើស្វ័យវាយតម្លៃប្រចាំខែរបស់សិស្សម្នាក់ៗ និងរបស់គ្រូបង្រៀនពិតប្រាដកមែន ហើយឧបករណ៍នេះក្លាយជាសាក្សីរបស់សិស្សម្នាក់ៗ។

លទ្ធផលស្វ័យវាយតម្លៃរបស់សិស្សម្នាក់ៗ និងរបស់គ្រូបង្រៀនប្រចាំខែ ត្រូវបានបូកសរុប និងរាយការណ៍ឱ្យដល់មិត្តរួមថ្នាក់ និងគ្រូបង្រៀន បានដឹងជារៀងរាល់ខែតាមថ្ងៃដែលសិស្ស គ្រូបង្រៀន និងក្រុមប្រឹក្សាយុវជននិងកុមារឯកភាពគ្នា។ ការធ្វើរបាយការណ៍ប្រចាំខែនេះសិស្សម្នាក់ៗ នឹងត្រូវអានលទ្ធផលដែលសម្រេចបានប្រៀបធៀបទៅនឹងលទ្ធផលរំពឹងទុក ដែលបានកំណត់ក្នុងឧបករណ៍ស្វ័យវាយតម្លៃរបស់សិស្សម្នាក់ៗ និងរបស់គ្រូបង្រៀន។

## ៣ សម្របសម្រួលក្រុមសិស្សឱ្យបង្កើត និងអនុវត្តគោលការណ៍(បទបញ្ជាផ្ទៃក្នុង)ថ្នាក់រៀន

ក្រុមប្រឹក្សាយុវជននិងកុមាររបស់សាលារៀនជួបប្រជុំពិភាក្សាជាមួយសិស្សទាំងអស់ក្នុងថ្នាក់ ដើម្បីចលនាឱ្យសិស្សម្នាក់ៗបានបញ្ចេញគំនិត យោបល់ និងសរសេរចងក្រងបង្កើតជាគោលការណ៍ថ្នាក់រៀន។ គោលការណ៍ថ្នាក់រៀនដែលជាគំនិត យោបល់របស់សិស្សម្នាក់ៗបានបង្ហាញពីលទ្ធផលរំពឹងទុក និងសកម្មភាពសម្រាប់គោរព និងប្រតិបត្តិទាំងអស់គ្នា។ ខ្លឹមសារសម្រាប់សិស្សកំណត់ ក្នុងគោលការណ៍ថ្នាក់រៀន គឺជាសំណូមពរទាក់ទងទៅនឹងសកម្មភាព កាយវិការ ឥរិយាបថ និងពាក្យសម្តីដែលក្នុងនោះមានពីសិស្សម្នាក់ៗ ទៅកាន់សិស្សរួមថ្នាក់ ពីសិស្សក្នុងថ្នាក់ទៅកាន់គ្រូបង្រៀន ទៅកាន់ឪពុកម្តាយ ពីឪពុកម្តាយទៅកូន និងពីឪពុកម្តាយទៅគ្រូបង្រៀន ដែលធ្វើឱ្យមានភាពងាយស្រួលដល់ការសិក្សារបស់សិស្ស និងគ្រូបង្រៀន ដូចជា៖ (១)ម៉ោងចូលរៀននិងចេញពីរៀន។ (២)ឥរិយាបថក្នុងពេលកំពុងរៀនមេរៀនជាមួយគ្រូ។ (៣)

ការចូលរួមក្នុងសកម្មភាពរៀន និងបង្រៀន។ (៤)ការសម្រេចចិត្តក្នុងការអនុវត្តគោលការណ៍ថ្នាក់រៀន។ (ឧបសម្ព័ន្ធទី៦៖ គោលការណ៍ឯកភាពរវាងគ្រូ និងសិស្សក្នុងថ្នាក់រៀន)

ខ្លឹមសារនៃគោលការណ៍ថ្នាក់រៀននោះ ប្រធានថ្នាក់ ឬតំណាងក្រុមសិស្ស អានខ្លឹមសារគោលការណ៍ទាំងស្រុងឱ្យបានឮៗ យឺតៗ និងច្បាស់ៗ ដើម្បីសិស្សក្នុងថ្នាក់ទាំងអស់ និងគ្រូបង្រៀនបានស្តាប់ ដែលជាសារ និងជាព័ត៌មានបង្ហាញថា ក្នុងថ្នាក់រៀនមួយមានគោលការណ៍មួយ ហើយគ្រប់អ្នកពាក់ព័ន្ធ ត្រូវគោរពជាដាច់ខាត ព្រោះគោលការណ៍នេះក្លាយជាកស្តុតាង យ៉ាងសំខាន់សម្រាប់ឆ្លុះបញ្ចាំងរាល់សកម្មភាពទាំងឡាយ ដែលសិស្ស ឪពុកម្តាយ និងគ្រូបង្រៀនបាននិងកំពុងប្រតិបត្តិប្រចាំថ្ងៃ។ គោលការណ៍ថ្នាក់រៀនអាចសរសេរបានលើក្រដាសកាតុង ក្តារខៀន បន្ទះក្តារ ក្រដាសផ្ទាំងធំ និងដាក់តាំង ទៅតាមស្ថានភាពជាក់ស្តែងរបស់ថ្នាក់រៀនដែលបង្កភាពងាយស្រួលដល់ការអាន។

ជានាគោលការណ៍ថ្នាក់រៀននេះ ត្រូវបានថែទាំ និងធ្វើបច្ចុប្បន្នភាពលើខ្លឹមសារព្រមទាំងធ្វើរបាយការណ៍បូកសរុបលទ្ធផល នៃការអនុវត្តគោលការណ៍ប្រចាំខែដើម្បីរាយការណ៍ជូនគ្រូបន្ទុកថ្នាក់ គណៈកម្មាធិការប្រតិបត្តិក្រុមប្រឹក្សាយុវជននិងកុមារ និងគណៈគ្រប់គ្រងសាលារៀន។

## ៤ វាយតម្លៃការងារសកម្មភាពរបស់ថ្នាក់រៀន សម្រាប់រាយការណ៍ទៅនាយក និងគណៈកម្មការទ្រទ្រង់សាលា

ក្រុមប្រឹក្សាយុវជននិងកុមាររបស់សាលារៀន ជួបប្រជុំជាមួយសាខាក្រុមប្រឹក្សាយុវជននិងកុមារថ្នាក់ និងសិស្សក្នុងថ្នាក់ទាំងអស់ពិភាក្សាគ្នាដើម្បីចូលរួមអនុវត្តសកម្មភាពសំខាន់ៗរបស់សាលារៀន។ ខ្លឹមសារសកម្មភាពដែលសិស្សអនុវត្តមានដូចជា៖ (១)ផ្នែកសិក្សា និងបណ្ណាល័យ (២)ផ្នែកសង្គ្រោះ និងជួយសង្គម (៣)ផ្នែករដ្ឋបាល និងហិរញ្ញវត្ថុ (៤)ផ្នែកផ្សព្វផ្សាយ (៥)ផ្នែកសិល្បៈ កីឡា និងវប្បធម៌ (៦)ផ្នែកសុខភាព អនាម័យ បរិស្ថាន និងបំណិនជីវិត (៧)ផ្នែកក្លឹបសិក្សាតាមផ្ទះ ក្នុងភូមិ និងក្នុងសហគមន៍ ដែលអាចជួយកុមារក្នុងសាលារៀន និងក្រៅសាលារៀនបានរៀន និងបានចូលរៀន (៨)ផ្នែកវិន័យ សណ្តាប់ធ្នាប់ និងចលនាកុមារបីល្អ។ (ឯកសារយោងទី១៖ កម្មវិធីសាលាកុមារមេត្រី សមាសភាពទី៥ ការចូលរួមរបស់កុមារ គ្រួសារ និងសហគមន៍ <u>ប្រតិបត្តិរបស់ក្រុមប្រឹក្សាយុវជននិងកុមារ បោះពុម្ពឆ្នាំ២០១០</u>) និង (ឧបសម្ព័ន្ធទី៧៖ ឧទាហរណ៍ ឧបករណ៍វាយតម្លៃការងារសកម្មភាពរបស់សាលារៀន)

សរុបមកការវាយតម្លៃការងារសកម្មភាពរបស់ថ្នាក់រៀន សម្រាប់រាយការណ៍ទៅនាយក និងគណៈកម្មការទ្រទ្រង់សាលា គឺត្រូវធ្វើឡើងជាប្រចាំតាមខែនិមួយៗ ដោយបូកសរុប និងរាយការណ៍ឱ្យដល់មិត្តរួមថ្នាក់ និងគ្រូបង្រៀន បានដឹង ជារៀងរាល់ខែតាមថ្ងៃដែលសិស្ស គ្រូបង្រៀន និងក្រុមប្រឹក្សាយុវជននិងកុមារបានព្រមព្រៀងគ្នា។ ការធ្វើរបាយការណ៍ប្រចាំខែនេះសិស្សម្នាក់ៗ នឹងត្រូវអានលទ្ធផលដែលបានអនុវត្តប្រៀបធៀបទៅនឹងលទ្ធផលរំពឹងទុកដែលបានកំណត់ក្នុងឧបករណ៍វាយតម្លៃ ។

## ង សកម្មភាពការងារក្រុមប្រឹក្សាយុវជននិងកុមារសាលារៀន

### ១ ជួយដល់កុមារក្នុងថ្នាក់រៀន និងសាលារៀនលើការងាររៀនសូត្រ

ក្រុមប្រឹក្សាយុវជននិងកុមាររបស់សាលារៀន ជួបប្រជុំជាមួយសាខាក្រុមប្រឹក្សាយុវជននិងកុមារថ្នាក់រៀន។ សាខាក្រុមប្រឹក្សាយុវជននិងកុមារថ្នាក់រៀនជួបប្រជុំជាមួយសិស្សក្នុងថ្នាក់ទាំងអស់ ពិភាក្សាគ្នាដោយជ្រើសរើសយកថ្ងៃណាមួយដែលមិនប៉ះពាល់ដល់ម៉ោងរៀន ដើម្បីជួយសិស្សក្នុងថ្នាក់លើការរៀនសូត្រតាមរយៈការរៀបចំកន្លែងរៀននៅផ្ទះខ្លួនឯង នៅផ្ទះជិតខាង និងកន្លែងប្រមូលផ្តុំក្នុងសហគមន៍ (ឧបសម្ព័ន្ធទី៣.ក៖ ឧទាហរណ៍បញ្ជីឈ្មោះកូនក្មួយដែលត្រូវរៀន ឈ្មោះអ្នកសម្របសម្រួលជួយដាស់តឿនកូនក្មួយបានរៀន ម៉ោងរៀន សម្រាប់រៀននូវផ្ទះខ្លួនឯង និងឧបសម្ព័ន្ធទី៣.ខ៖ ឧទាហរណ៍ការរៀបចំសៀវភៅកត់ត្រាដំណើរការកន្លែងរៀន ផ្ទះជិតគ្នា និងកន្លែងរៀនក្នុងសហគមន៍ដោយបញ្ជាក់ ម៉ោងរៀន មេរៀន និងអ្នកបានមករៀន)។

សរុបមកកន្លែងរៀន និងដំណើរការរៀនសូត្រនេះប្រព្រឹត្តទៅបាន ដោយមានការគ្រប់គ្រងចាត់ចែង និងទទួលខុសត្រូវដោយផ្ទាល់ពីសំណាក់មេភូមិ មេឃុំ បុព្វជិតសាសនា ឬអ្នកពាក់ព័ន្ធដទៃទៀតដោយមានកិច្ចសហការជាមួយគ្រូបង្រៀន ក្រុមប្រឹក្សាយុវជននិងកុមាររបស់សាលារៀន និងគណៈគ្រប់គ្រងសាលារៀនផងដែរ។ ក្រៅពីរៀបចំកន្លែងរៀនដូចបានរៀបរាប់ខាងលើក្រុមប្រឹក្សាយុវជននិងកុមារក៏ត្រូវមានភារកិច្ចរៀបចំឱ្យមានសកម្មភាពប្រកួតអានរវាងសិស្សនិងសិស្សក្នុងថ្នាក់ រវាងថ្នាក់និងថ្នាក់ រវាងសាលានិងសាលា រវាងភូមិនិងភូមិ ដើម្បីយកលទ្ធផលនោះទៅប្រកួតផ្តាច់ព្រ័ត្រក្នុងទិវាជាតិអំណានថ្ងៃទី១១ មីនាដែលតែងប្រព្រឹត្តទៅជារៀងរាល់ឆ្នាំស្របតាមគោលការណ៍ណែនាំរបស់ក្រសួងអប់រំ យុវជន និងកីឡា។ (ឧបសម្ព័ន្ធទី៤៖ ដំណើរការរៀបចំព្រឹត្តការណ៍ប្រកួតអំណាន)

### ២ ជួយកុមារឱ្យមានសមត្ថភាពរាយការណ៍ ពីបញ្ហាដែលកើតឡើងចំពោះកុមារនៅសាលារៀន

ក្រុមប្រឹក្សាយុវជននិងកុមាររបស់សាលារៀន ជួបប្រជុំជាមួយសាខាក្រុមប្រឹក្សាយុវជននិងកុមារថ្នាក់រៀន។ សាខាក្រុមប្រឹក្សាយុវជននិងកុមារថ្នាក់រៀនជួបប្រជុំជាមួយសិស្សក្នុងថ្នាក់ទាំងអស់ពិភាក្សាគ្នាដោយជ្រើសរើសយកថ្ងៃណាមួយដែលមិនប៉ះពាល់ដល់ម៉ោងរៀន ដើម្បីពិភាក្សាបង្កើតប្រព័ន្ធរាយការណ៍ និងផ្តល់សេវាដល់កុមារជួបការលំបាក និងរងគ្រោះ ដែលបង្ហាញពីទំនួលខុសត្រូវ ហើយមានសមាសភាពដែលអាចរាយការណ៍បានទាន់ពេលវេលា ។ រចនាសម្ព័ន្ធ សមាសភាព តួនាទី លេខទូរស័ព្ទសម្រាប់ទំនាក់ទំនង ដែលបានកំណត់នៅក្នុងប្រព័ន្ធរាយការណ៍ និងផ្តល់សេវាដល់កុមារជួបការលំបាក និងរងគ្រោះ គឺជាបុគ្គលដែលមានទំនួលខុសត្រូវខ្ពស់ងាយស្រួលទំនាក់ទំនង ព្រមទាំងពេញចិត្តធ្វើការជាមួយស្ថាប័នអប់រំដូចជា៖ សួរនាំការរៀនសូត្រ ស្ថានភាពរស់នៅ ផ្តល់ព័ត៌មានត្រឡប់ដល់មាតាបិតា អាព្យាបាលសិស្ស។ល។ (ឧបសម្ព័ន្ធទី៥៖ ឧទាហរណ៍តារាងយន្តការប្រព័ន្ធរាយការណ៍ និងផ្តល់សេវាដល់កុមារជួបការលំបាក និងរងគ្រោះ)

ប្រព័ន្ធរាយការណ៍ និងផ្តល់សេវាដល់កុមារជួបការលំបាក និងរងគ្រោះ អាចសរសេរលើក្រដាសការតុង ក្រដាសផ្ទាំងធំ ឬក្តារខៀនសម្រាប់ដាក់តាំងទៅតាមស្ថានភាពជាក់ស្តែងរបស់សាលារៀន

(ក្នុងបន្ទប់រៀន ទីចាត់ការ ក្នុងសហគមន៍...) ដើម្បីប្រកាសឱ្យបានដល់មិត្តរួមថ្នាក់ គ្រូបង្រៀន នាយក គណៈកម្មការអភិវឌ្ឍន៍សាលារៀន អាជ្ញាធរមូលដ្ឋាន សហគមន៍ មាតាបិតា អាណាព្យាបាលសិស្សបានស្តាប់ បានដឹងទុកជាសាក្សី ដើម្បីរកដំណោះស្រាយជួយអន្តរាគមន៍បានទាន់ពេលវេលា។

### ៣ ជួយកុមារឱ្យមានសមត្ថភាពក្នុងការដោះស្រាយបញ្ហា ដែលកើតមានឡើងចំពោះកុមារនៅសាលារៀន

ក្រុមប្រឹក្សាយុវជននិងកុមាររបស់សាលារៀន ជួបប្រជុំជាមួយសាខាក្រុមប្រឹក្សាយុវជននិងកុមារថ្នាក់រៀន។ សាខាក្រុមប្រឹក្សាយុវជននិងកុមារថ្នាក់រៀនជួបប្រជុំជាមួយសិស្សក្នុងថ្នាក់ទាំងអស់ពិភាក្សាគ្នា ដោយជ្រើសរើសយកថ្ងៃណាមួយដែលមិនប៉ះពាល់ដល់ម៉ោងរៀន ដើម្បីប្រមូលព័ត៌មាន ព្រមទាំងរាយការណ៍អំពីព្រឹត្តិការណ៍ដែលបានកើតឡើងនៅតាមថ្នាក់រៀន និងសាលារៀនប្រចាំខែ។ ខ្លឹមសារសកម្មភាពដែលបានដោះស្រាយមានដូចជា៖ (១)លទ្ធផលនៃការធ្វើផែនការសកម្មភាពរបស់សិស្សម្នាក់ៗតាមថ្នាក់ (២)លទ្ធផលនៃការស្វ័យវាយតម្លៃសិស្ស និងគ្រូបង្រៀនប្រចាំខែ ការអនុវត្តការងារសាខាក្រុមប្រឹក្សាយុវជននិងកុមារតាមថ្នាក់ (៣)លទ្ធផលនៃការអនុវត្តសកម្មភាពក្រុមប្រឹក្សាយុវជននិងកុមារក្នុងសាលារៀនទាំង ៨ ផ្នែក។

ដំណោះស្រាយបញ្ហាដែលកើតមានឡើង ចំពោះកុមារនៅសាលារៀនអាចសរសេរ ជាលាយលក្ខណ៍អក្សរនៅក្នុងសៀវភៅកំណត់ត្រា ឬក្រដាសរ៉ាម ហើយអានឱ្យមិត្តរួមថ្នាក់ គ្រូបង្រៀន នាយក គណៈកម្មការអភិវឌ្ឍន៍សាលារៀន អាជ្ញាធរមូលដ្ឋាន សហគមន៍ អាណាព្យាបាលបានស្តាប់ បានដឹង និងបានបញ្ជាក់ថា រាល់ការដោះស្រាយមានឯកសាររក្សាតម្កល់ទុកជាភស្តុតាង។

ជារៀងរាល់ខែ តំណាងក្រុមប្រឹក្សារបស់សាលារៀន ចូលរួមប្រជុំជាមួយគណៈកម្មការអភិវឌ្ឍសាលារៀន គណៈគ្រប់គ្រងសាលារៀន និងគ្រូទទួលបន្ទុកថ្នាក់ដើម្បីគេអាចរាយការណ៍ពីលទ្ធផលរីកចម្រើន បញ្ហាប្រឈម និងផែនការសកម្មភាពដែលនឹងត្រូវធ្វើបន្តនៅខែបន្ទាប់ និងសំណូមពរដល់អ្នកពាក់ព័ន្ធដើម្បីជួយដោះស្រាយ។ លើសពីនោះទៅទៀត តំណាងក្រុមប្រឹក្សាយុវជននិងកុមារក៏អាចយកលទ្ធផលរីកចម្រើន និងបញ្ហាប្រឈមទាំងនោះជូនអង្គប្រជុំជាមួយ ក្រុមប្រឹក្សាឃុំ សង្កាត់ និងស្ថាប័នផ្សេងទៀតផងដែរ។

# ឧបសម្ព័ន្ធ

## ឧបសម្ព័ន្ធទី១៖ ឧទាហរណ៍តារាងផែនការសកម្មភាពប្រចាំខែរបស់សិស្សម្នាក់ៗ

សាលាបឋមសិក្សា..................................................ឈ្មោះ

ក តារាងប្តេជ្ញាបង្កើន ឬកែលម្អលទ្ធផលសិក្សា

| មុខវិជ្ជា | ពិន្ទុទទួលបានខែមុន |
|---|---|
| ភាសាខ្មែរ | |
| បំណិនជីវិត | |
| គណិតវិទ្យា | |

ខ តារាងផែនការសកម្មភាពប្រចាំខែរបស់សិស្ស

| សកម្មភាព | អ្នកជំនួយ | 1 | 2 | 3 | 4 | 5 | 6 | 7 | 8 | 9 | 10 | 11 | 12 | 13 | 14 |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| **ភាសខ្មែរ** | | | | | | | | | | | | | | | |
| អានស្រៈ | | | | | | | | | | | | | | | |
| អានព្យញ្ជនៈ | | | | | | | | | | | | | | | |
| អានពាក្យ | | | | | | | | | | | | | | | |
| អានឃ្លា | | | | | | | | | | | | | | | |
| អានអត្ថបទ | | | | | | | | | | | | | | | |
| និទានរឿងខ្លី | | | | | | | | | | | | | | | |
| សរសេរពាក្យ | | | | | | | | | | | | | | | |
| តែងឃ្លាៈ | | | | | | | | | | | | | | | |
| តែងអត្ថបទ | | | | | | | | | | | | | | | |
| **គណិតវិទ្យា** | | | | | | | | | | | | | | | |
| បូកលេខ | | | | | | | | | | | | | | | |
| ដកលេខ | | | | | | | | | | | | | | | |
| ចែកលេខ | | | | | | | | | | | | | | | |

 វិស្ស.................................ថ្នាក់ទី.......................សម្រាប់ខែ..............

| | ពិន្ទុប្ដេជ្ញាក្នុងខែ |
|---|---|
| | |
| | |
| | |

| ថ្ងៃអនុវត្តក្នុងខែ | | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| 15 | 16 | 17 | 18 | 19 | 20 | 21 | 22 | 23 | 24 | 25 | 26 | 27 | 28 | 29 | 30 | 31 |
| | | | | | | | | | | | | | | | | |
| | | | | | | | | | | | | | | | | |
| | | | | | | | | | | | | | | | | |
| | | | | | | | | | | | | | | | | |
| | | | | | | | | | | | | | | | | |
| | | | | | | | | | | | | | | | | |
| | | | | | | | | | | | | | | | | |
| | | | | | | | | | | | | | | | | |
| | | | | | | | | | | | | | | | | |
| | | | | | | | | | | | | | | | | |
| | | | | | | | | | | | | | | | | |
